ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

# សៀវភៅណែនាំ

# ស្តីពី ភារកិច្ច និងកាតព្វកិច្ច

# របស់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ

# ក្នុងដំណើរការរៀបចំការបោះឆ្នោត

# សាររបស់ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## លោក លោកស្រីមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ជាទីរាប់អាន

គ.ជ.ប មានជំនឿជាក់ថា នៅពេលជនគ្រប់រូបដែលពាក់ព័ន្ធនឹងការបោះឆ្នោតយល់ដឹងច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន ពួកគេនឹងចូលរួមចំណែកបានកាន់តែប្រសើរឡើង ធ្វើឱ្យការបោះឆ្នោតដោយសេរី និងយុត្តិធម៌មួយសម្រេចបានជោគជ័យ ។

លោក លោកស្រី ជាមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ នឹងដើរតួនាទីសំខាន់ក្នុងការផ្តល់ព័ត៌មាន និង លើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនឱ្យចូលរួមក្នុងគ្រប់ទិដ្ឋភាពនៃដំណើរការបោះឆ្នោត ។ លោក អ្នកស្ថិតក្នុងស្ថានភាពតែមួយ ក្នុងការបង្កើតបរិយាកាសជឿទុកចិត្តគ្នា អធ្យាស្រ័យ និងគោរពសិទ្ធិសេរីភាពបុគ្គល ដែលជាកត្តាចំបងធ្វើឱ្យការបោះឆ្នោតដោយសេរី និងយុត្តិធម៌ទទួលបានជោគជ័យ ។

សៀវភៅនេះមានគោលបំណងផ្តល់ជូននូវកំរងវិធាន ភារកិច្ច និងកាតព្វកិច្ចនានា មានលក្ខណៈច្បាស់លាស់ងាយយល់ ដែលលោក លោកស្រីមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ អាចអនុវត្តបាន ។ កំរងវិធាន ភារកិច្ច និងកាតព្វកិច្ចទាំងនេះពិតជា មិនគ្រាន់តែអនុវត្តក្នុងដំណាក់កាលបោះឆ្នោតប៉ុណ្ណោះទេ ថែមទាំងត្រូវយកមកអនុវត្តក្នុងសកម្មភាពនានាពាក់ព័ន្ធនឹងដំណើរការបោះឆ្នោតផ្សេងទៀត ដូចជាការផ្តល់ព័ត៌មាន ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងការទទួលខុសត្រូវផ្សេងទៀតក្រៅអំឡុងពេលបោះឆ្នោត ។

ជាការពិត ដើម្បីលើកមុខមាត់របស់លោកអ្នកជាសមាសភាគអព្យាក្រឹតមួយនៃរដ្ឋបាលសាធារណៈ ខ្ញុំយល់ថាជានិច្ចកាល លោកអ្នកត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ចំពោះភារកិច្ច និងកាតព្វកិច្ច ដូចមានចែងក្នុងសៀវភៅនេះ ។

ដូចនេះហើយទើបខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងជួយលោក អ្នកទាំងអស់ឱ្យបំពេញភារកិច្ចបានជោគជ័យ និង ជួយគាំទ្រដល់ដំណើរការរៀបចំការបោះឆ្នោតឱ្យប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងមានតម្លាភាព ។

ខ្ញុំសូមអរគុណចំពោះការចូលរួមសហការរបស់លោក អ្នក ។

**អ៊ឹម សូស្ឋី**

**ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

# មាតិកា

ទំព័រ


សេចក្ដីផ្ដើម ........................................................ ១

ជំហរអព្យាក្រឹត  ឥតលំអៀង ........................................ ២

ជៀសវាងការគំរាមកំហែង ............................................ ៥

សហការជាមួយនឹងអាជ្ញាធរបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ................... ៤

# សេចក្ដីផ្ដើម

ភារកិច្ច និងកាតព្វកិច្ចដែលត្រូវបានបញ្ចូលក្នុងសៀវភៅនេះយោងទៅតាម ៖

- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- អនុក្រឹត្យលេខ ២២ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០០២ ស្ដីពីការធ្វើវិមជ្ឈការ អំណាច តួនាទី និង ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។
- សេចក្ដីណែនាំរបស់ក្រសួងមហាផ្ទៃលេខ ០០៤ សណន ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៦ ស្ដីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្ដូរមេភូមិ ការតែងតាំងជំនួយការ និង តួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ ។
- សេចក្ដីណែនាំរួមលេខ ០១០ សណន ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៦ របស់ក្រសួងមហាផ្ទៃ និង គជប ស្ដីពីការផ្ដល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។
- អំណាចជាទូទៅដែលត្រូវបានប្រគល់ជូន គ.ជ.ប ក្នុងការចាត់គ្រប់វិធានការសមស្របដើម្បីធានានូវការបោះឆ្នោតមួយដោយសេរី និង យុត្តិធម៌ ដូចមានចែងក្នុងមាត្រាទី ១៦ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

សៀវភៅនេះជម្រាបជូននូវគតិយាបទអនុវត្តការងារសំខាន់ៗ ៣ គឺ ៖

១ - ជំហរអព្យាក្រឹត ឥតលំអៀង

២ - ជៀសវាងការគំរាមកំហែង

៣ - សហការជាមួយអាជ្ញាធរបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

# ជំហរអព្យាក្រឹត ឥតលំអៀង




មេភូមិពុំត្រូវបញ្ចេញទស្សនៈនយោបាយផ្ទាល់ខ្លួនទៅលើអ្នកភូមិរបស់គាត់

# ប្រធានភូមិត្រូវតែអព្យាក្រឹត

ភាពអព្យាក្រឹត និងឥតលំអៀងនេះត្រូវបានចែងនៅក្នុងច្បាប់ ដោយហេតុថា មេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ មានកាតព្វកិច្ចបំរើអ្នកភូមិគ្រប់ៗគ្នា ។ លោក អ្នក ត្រូវចងចាំថា លោក អ្នកត្រូវបានបោះឆ្នោតជ្រើសរើស ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដូច្នេះ លោក អ្នកចាំបាច់ត្រូវតែប្រកាន់ជំហរអព្យាក្រឹត ឥតលំអៀងក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។




**មេភូមិត្រូវបំរើអ្នកភូមិគ្រប់ៗគ្នាដោយពុំប្រកាន់និន្នាការនយោបាយរបស់ពួកគេ**

ប្រការនេះមានន័យថា នៅពេលដែល លោក អ្នកកំពុងបំពេញភារកិច្ចក្នុងឋានៈជា មេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ លោក អ្នក មិនត្រូវបង្ហាញជាចំហនូវគណបក្សនយោបាយរបស់ខ្លួន ឬ បង្ហាញការគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយជាសាធារណៈឡើយ ។

ប្រការនេះក៏មានន័យផងដែរថា នៅពេលដែលលោក អ្នកកំពុងធ្វើសកម្មភាពក្នុងសមត្ថកិច្ចផ្លូវការរបស់ខ្លួន ក្នុងឋានៈជាមេភូមិ អនុប្រធានភូមិ ឬ សមាជិកភូមិ លោក អ្នកមិនអាចប្រើប្រាស់សមត្ថកិច្ច និងឋានៈរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយ

ណាមួយ ឬព្យាយាមប្រើឥទ្ធិពលទៅលើអ្នកភូមិ ឬជ្រៀតជ្រែកទៅក្នុងទស្សនៈរបស់បុគ្គល ឬទៅក្នុងការជ្រើសរើសរបស់ប្រជាពលរដ្ឋក្នុងភូមិរបស់លោក អ្នកទោះតាមរូបភាពណាក៏ដោយ ។ លោក អ្នកនៅតែមានសិទ្ធិបញ្ចេញមតិយោបល់ផ្ទាល់ខ្លួនរបស់លោក អ្នកនិងនៅតែមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវិតនយោបាយ គណបក្សដែលលោក អ្នកជ្រើសរើស ប៉ុន្តែលោក អ្នកគប្បីធ្វើសកម្មភាពទាំងនេះក្នុងឋានៈជាបុគ្គលឯកជន ពោលគឺមិនមែន ក្នុងតួនាទីជា មេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិឡើយ ។

តាមន័យធម្មតា លោក អ្នកមិនត្រូវប្រើប្រាស់ឋានៈរបស់លោក អ្នកជាមេភូមិ អនុប្រធានភូមិ ឬ សមាជិកភូមិ ដើម្បីព្យាយាមដាក់ជំរើសនយោបាយឯកជនរបស់លោក អ្នក ទៅលើអ្នកភូមិគ្រប់រូបឡើយ ពីព្រោះក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជាពលរដ្ឋមានសិទ្ធិក្នុងការបញ្ចេញទស្សនៈផ្ទាល់ខ្លួន ដោយគ្មានការគាបសង្កត់ពីអាជ្ញាធរ ។ គ្មានអ្នកណាម្នាក់ត្រូវបានសមត្ថកិច្ចដាក់ទោសដោយសារហេតុផលជំនឿនយោបាយរបស់ពួកគេឡើយ ។

ដើម្បីប្រកាន់ជំហរអព្យាក្រឹត ឥតលំអៀង លោក អ្នកត្រូវផ្តល់សេវា និងព័ត៌មាន ដូច១គ្នា ជូនអ្នកភូមិគ្រប់ៗរូប ដោយមិនប្រកាន់និន្នាការនយោបាយរបស់ពួកគាត់ ។

ទាំងនេះមានន័យថាលោក អ្នកមិនត្រូវលាក់ព័ត៌មាន ឬផ្សព្វផ្សាយព័ត៌មាន ដល់អ្នកភូមិទាំងឡាយ ដោយមានការរើសអើងផ្អែកទៅលើគណបក្សនយោបាយ ដែលពួកគាត់គាំទ្រនោះឡើយ ។ ឧទាហរណ៍ថា ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតគឺជាភារកិច្ចផ្លូវការ ដែលលោក អ្នកត្រូវបំពេញក្នុងឋានៈជា មេភូមិ អនុប្រធានភូមិ ឬ សមាជិកភូមិ ។ លោក អ្នកត្រូវធានាថាការចែកប័ណ្ណព័ត៌មាននេះត្រូវបានអនុវត្ត ដោយយុត្តិធម៌ចំពោះអ្នកភូមិគ្រប់ៗរូប ។ លោក អ្នកត្រូវយកចិត្តទុកដាក់ជាពិសេសថា លោក អ្នកមិនបានធ្វើឱ្យមានការចាប់អារម្មណ៍ថា លោក អ្នកកំពុងបំពេញភារកិច្ចនេះ ដោយលំអៀងទៅលើគណបក្សណាមួយឡើយ ។

ប្រសិនបើលោក អ្នកប្រព្រឹត្តផ្ទុយពីអ្វីដែលបានរៀបរាប់ខាងលើនេះ លោក អ្នកពិតជានឹងទទួលការទិទៀនជាមិនខាន ពីព្រោះ លោក អ្នកកំពុងតែធ្វើឱ្យប្រជាធិបតេយ្យនៅប្រទេសកម្ពុជាអាប់អោន ហើយសំខាន់ជាងនេះទៅទៀតនោះ លោក អ្នក នឹងត្រូវទទួលទោសតាមច្បាប់ ។

# ជៀសវាងការគំរាមកំហែង



មេភូមិពុំមានសិទ្ធិសួរអ្នកភូមិអំពីគណបក្សនយោបាយដែលពួកគាត់បោះឆ្នោតគាំទ្រឡើយ




មានពេលខ្លះ សកម្មភាពរបស់លោកអ្នកក្នុងឋានៈជាមេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិអាចមានឥទ្ធិពលគំរាមកំហែងដល់អ្នកភូមិ ឬធ្វើឱ្យពួកគាត់មានអារម្មណ៍ថាលោក អ្នកកំពុងធ្វើសកម្មភាពដោយមិនអព្យាក្រឹត ។

ឧទាហរណ៍ ការប្រមូលយកឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងៗរបស់អ្នកភូមិ ទោះដោយសារ ហេតុផលអ្វីក៏ដោយសុទ្ធតែត្រូវបានហាមឃាត់ ព្រោះវាអាចត្រូវបានគេបកស្រាយថាជាការគំរាមកំហែង ឬជាមូលហេតុនយោបាយ ។ ប្រជាពលរដ្ឋអាចមានការភ័យខ្លាចថាលោក អ្នកចង់រារាំង ពួកគាត់មិនឱ្យបោះឆ្នោត ។

ស្ថានភាពផ្សេងទៀតដែលត្រូវបានគេបកស្រាយថាលោក អ្នកបំភិតបំភ័យអ្នកភូមិ របស់លោក អ្នកនោះគឺនៅពេលលោកអ្នករារាំងបំណងចូលរួមក្នុងកិច្ចប្រជុំជាសាធារណៈ ឬ គណបក្សនយោបាយ ឬ ទទួលព័ត៌មានពីគណបក្សនយោបាយផ្សេងៗ

របស់អ្នកភូមិ។ ត្រង់ចំណុចនេះលោក អ្នកគប្បីប្រុងប្រយ័ត្នថាសេរីភាពក្នុងការបញ្ចេញមតិផ្ទាល់ខ្លួនរបស់អ្នកភូមិ មិនត្រូវបាន រារាំងដោយសកម្មភាពរបស់លោក អ្នកឡើយ។ ពាក់ព័ន្ធនឹងកិច្ចប្រជុំ វិធានដូចគ្នានេះត្រូវយកមកអនុវត្ត ចំពោះអ្នកភូមិ គ្រប់ៗរូប ពោលគឺ នៅពេលមានតម្រូវការ ស្នើសុំការអនុញ្ញាតធ្វើមីទិញ លោក អ្នកត្រូវអនុវត្តលក្ខខណ្ឌតម្រូវ និង នីតិវិធីដូចគ្នា ដោយគ្មានការរើសអើង ។

មានឧទាហរណ៍ជាច្រើនផ្សេងទៀតចំពោះសកម្មភាពរបស់លោក អ្នកដែលអាចត្រូវបានបកស្រាយថាជាការគំរាមកំហែង ដូចជាលោក អ្នកព្យាយាមសួរអ្នកភូមិអំពីគណបក្សនយោបាយដែលពួកគាត់ពេញចិត្ត ឬមិនពេញចិត្ត ឬព្យាយាមផ្តល់ដំបូន្មានដល់ ពួកគាត់ ឬបញ្ចុះបញ្ចូលពួកគាត់ឱ្យបោះឆ្នោតគាំទ្រគណបក្សណាមួយ ។ ទោះបីជាលោក អ្នកធ្វើសកម្មភាពទាំងនេះក្នុងបំណង ល្អក៏ដោយ ក៏ច្បាប់ហាមប្រាមទាំងស្រុងដែរ ។

ក្នុងឋានៈជាមេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ លោក អ្នកមិនអាចធ្វើជាអ្នកផ្សព្វផ្សាយឱ្យគណបក្សនយោបាយ ជាក់លាក់ណាមួយឡើយ ។ ឥទ្ធិពលរបស់លោក អ្នក មានទំហំធំធេងណាស់ចំពោះអ្នកភូមិ ហើយសកម្មភាពរបស់លោកអ្នកអាច ត្រូវបានគេចាត់ទុកថាមិនយុត្តិធម៌ ចំពោះគណបក្សផ្សេងនិងគ្មានលទ្ធិប្រជាធិបតេយ្យ ។

តាមគំនិតផ្តួចផ្តើមខ្លះទៀតដែលលោក អ្នកអាចនឹងអនុវត្តក្នុងឋានៈជា មេភូមិ អនុប្រធានភូមិ ឬ សមាជិកភូមិ លោក អ្នកត្រូវប្រុងប្រយ័ត្ន កុំបង្ហាញឱ្យមានការចាប់អារម្មណ៍ថា លោក អ្នកកំពុងតែព្យាយាមដោយផ្ទាល់ ឬដោយប្រយោលដើម្បីគំរាម កំហែង ឬបំភិតបំភ័យអ្នកបោះឆ្នោត ដោយសារតែនិន្នាការនយោបាយរបស់ពួកគាត់។

# សហការជាមួយនឹងអាជ្ញាធរបោះឆ្នោតគ្រប់លំដាប់ថ្នាក់



មេភូមិត្រូវសហការចែក ឬ/និងផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋដោយពុំមានការរើសអើង

ប្រការនេះមានន័យថាលោក អ្នកត្រូវអនុវត្តមុខងារ និងភារកិច្ច ដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវឱ្យធ្វើ ដោយហេតុថា ច្បាប់តម្រូវឱ្យក្រុមប្រឹក្សាឃុំ សង្កាត់សហការជាមួយនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត (គខ/កប) និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប)។



មេភូមិត្រូវសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ តំណាងគណបក្សនយោបាយ និងប្រជាពលរដ្ឋគ្រប់ៗរូប

ដូចនេះមន្ត្រីបោះឆ្នោតអាចត្រូវការជំនួយពីក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យជួយផ្ដល់ព័ត៌មានជូនសាធារណជន ក្នុងនោះមានការចែកឯកសារ ដូចជា ចែកខិតប័ណ្ណ សៀវភៅព័ត៌មាន ឬ ប័ណ្ណប្រកាស ។ ដោយហេតុថាលោក អ្នកជាមនុស្សសំខាន់ក្នុងការទំនាក់ទំនងរវាងក្រុមប្រឹក្សា ឃុំ សង្កាត់ និង អ្នកភូមិ លោក អ្នកចាំបាច់ត្រូវអនុវត្តការងារដែលឃុំ សង្កាត់ប្រគល់ឱ្យ ក្នុងនោះមានការគាំទ្រយ៉ាងសកម្មចំពោះដំណើរការបោះឆ្នោតដោយសេរី យុត្តិធម៌ និង អព្យាក្រឹត ។

ក្នុងសមត្ថកិច្ចនេះ គ.ជ.ប ស្នើសុំឱ្យ លោក អ្នកសហការក្នុងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងឯកសារផ្សេងៗ ដោយមិនគិតថ្លៃពីអ្នកបោះឆ្នោត ។ សូមបញ្ជាក់ជាថ្មីម្តងទៀតថាជាចាំបាច់លោក អ្នកត្រូវបំពេញការងាររបស់ខ្លួនតាមមធ្យោបាយដែលធ្វើឱ្យអ្នកភូមិរបស់លោក អ្នកជឿទុកចិត្តថាលោក អ្នកពិតជា ប្រកាន់ជំហរអព្យាក្រឹត ឥតលំអៀងប្រាកដមែន ។

មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិណាម្នាក់ដែលប្រព្រឹត្តខុសពីភារកិច្ចជាតំណាងឱ្យប្រជាពលរដ្ឋគ្រប់រូបក្នុងភូមិ ត្រូវបានចាត់ទុកថាបានធ្វើឱ្យមានកំហុសក្នុងការបំពេញការងាររបស់ខ្លួន ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចាត់វិធានការសមស្រប ដើម្បីផ្តន្ទាទោសចំពោះអ្នកប្រព្រឹត្តកំហុសទាំងនេះ ដោយយោងទៅតាមច្បាប់និង សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ។

កន្លងមកនេះ មានមេភូមិមួយចំនួនដែលត្រូវបានផ្តន្ទាទោសដោយសារតែការប្រព្រឹត្តផ្ទុយនឹងវិធានការណ៍ទាំងនេះ ។ ប៉ុន្តែពេលនេះជាឱកាសល្អដែលលោក អ្នក មានព័ត៌មានចាំបាច់គ្រប់គ្រាន់ក្នុងសៀវភៅនេះ ដើម្បីបំពេញតួនាទីរបស់ខ្លួនយ៉ាងប្រាកដប្រជាក្នុងចិត្ត ។

គ.ជ.ប សូមថ្លែងអំណរគុណចំពោះការអនុវត្តទៅតាមកាតព្វកិច្ច និងការទទួលខុសត្រូវរបស់លោក អ្នក ដែលទាំងនេះធ្វើឱ្យប្រជាពលរដ្ឋគ្រប់រូបមានមោទនភាព ចំពោះបរិយាកាសល្អប្រសើរនៃលទ្ធិប្រជាធិបតេយ្យ បរិស្ថានសន្តិភាព ការជឿទុកចិត្តគ្នា និងការគោរពគ្នាទៅវិញទៅមកក្នុងចំណោមប្រជាពលរដ្ឋ ដែលប្រការនេះទាមទារឱ្យមានការចូលរួមចំណែកពីលោកអ្នក ។

★★★★★★★★★★

# បោះពុម្ពផ្សាយដោយ

UNDP

*Cambodia*

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

២០០៧